នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | ៖ | ០០៤/២/០៧-០៩-២០០៩-អវតក/អបជ (អបជ ៦០) |
| ដាក់ទៅ | ៖ | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | ៖ | ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ |
| ភាគីអ្នកដាក់ | ៖ | អោ អាន |
| ភាសាដើម | ៖ | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2020, 11:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ អបជ៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

**ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សា សំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ**

---

**អ្នកដាក់ឯកសារ៖**
**សហមេធាវី**
មុំ លុដ្ឋ
Richard ROGERS
Göran SLUITER

**អ្នកទទួលឯកសារ៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ថុល
ចៅក្រម Kang Jin BAIK
ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា**
ជា លាង
Brenda J. Hollis

**អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង០០៤/២**

# សេចក្តីផ្តើម

1. តាមរយៈសហមេធាវីរបស់គាត់ (*"មេធាវីការពារក្តី"*) អោ អាន សូមធ្វើការឆ្លើយតបទៅនឹង *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ (“ចម្លើយតប”)*[1]។ ទោះជាមានសេចក្តីថ្លែងការណ៍ផ្ទុយគ្នារបស់ចៅក្រមជាតិ និងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះនៅក្នុងអនុស្សរណៈរៀងៗខ្លួនរបស់ពួកគាត់ដែលអាចធ្វើឱ្យការឆ្លើយតបនេះក្លាយជាអសារបង់[2] អោ អាន ដាក់ទឡ្ហីករណ៍របស់គាត់ ដើម្បីធានាថា សំណុំរឿងមានភាពត្រឹមត្រូវ និងមានសម្ភារឯកសារពាក់ព័ន្ធទាំងអស់ និងបញ្ជាក់បន្ថែមពីជំហរមិនត្រឹមត្រូវដែលសហព្រះរាជអាជ្ញាអន្តរជាតិ និងចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ បានលើកឡើង។

2. នៅក្នុង *ចម្លើយតប* សហព្រះរាជអាជ្ញាអន្តរជាតិអះអាងដោយមិនត្រឹមត្រូវថា “គោលជំហរស្វ័យប្រវត្តិ” គឺថាសំណុំរឿងរបស់ អោ អាន ត្រូវតែបន្តទៅជំនុំជម្រះ[3]។ គាត់បន្តបដិសេធលើអត្ថិភាព *ដីកាសម្រេចលើក លែងចោទប្រកាន់ប្រឆាំងនឹង អោ អាន (“ដីកាសម្រេចលើកលែងចោទប្រកាន់”)*[4] ដែលជាការសម្រេចសេចក្តីរួមរបស់ចៅក្រម អង្គបុរេជំនុំជម្រះ នៅក្នុង *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (“ការសម្រេចសេចក្តីរួម”* និង *“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍”)*[5] និងយោបល់របស់ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ ដែលបាន

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក (អបជ ៦០) *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹង សំណើរបស់ អោ អាន ស្នើសុំការបញ្ជាក់ថាវិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ (“ចម្លើយតប”)* ឯកសារ **D359/30 & D360/39** ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០។

[2] *អនុស្សរណៈចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ទាក់ទិននឹងការបញ្ជាក់សាជាថ្មីពីសេចក្តីសម្រេចលើសំណុំរឿង ០០៤/២ (“អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០”)* ដែលប្រធាន អង្គបុរេជំនុំជម្រះ បានផ្ញើទៅភាគី ទំព័រ ១-២ មានភ្ជាប់ជាឧបសម្ព័ន្ធ ១។ *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ទាក់ទិននឹងការបញ្ជូនសំណុំរឿង ០០៤/២ (“អនុស្សរណៈថ្ងៃទី ១២ ខែមីនា ឆ្នាំ២០២០”)* ដែលចៅក្រមអន្តរជាតិនៅ អង្គបុរេជំនុំជម្រះ ផ្ញើទៅភាគី ទំព័រ ១ មានភ្ជាប់ជាឧបសម្ព័ន្ធ ២។

[3] *ចម្លើយតប* កថាខណ្ឌ ១៣។

[4] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំងនឹង អោ អាន (“ដីកាសម្រេចលើកលែងចោទប្រកាន់”)* ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[5] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (“សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍”)* ឯកសារ **D359/24 & D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

បញ្ចប់សំណុំរឿងរួមគ្នាយ៉ាងមានប្រសិទ្ធភាព កាលពីជិតបីខែមុន[6]។

3. សហព្រះរាជអាជ្ញាអន្តរជាតិ ព្រមទាំងចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះនៅតែរក្សាជំហរ ដោយគ្មានមូលដ្ឋានថា យោបល់របស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ និង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[7] មានទម្ងន់ច្រើនជាងការសម្រេចសេចក្តីរួម យោបល់របស់ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ និង *ដីកាសម្រេចលើកលែងចោទប្រកាន់*[8]។ ការធ្វើបែបនេះ ពួកគាត់បានទុកចោល *ដីកាសម្រេចលើកលែងចោទប្រកាន់* ការសម្រេចសេចក្តីរួម និងសកម្មភាពរបស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ ដោយមិនពិចារណាដល់លក្ខណៈចម្រុះរបស់តុលាការដែល

---

[6] អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ បានតម្កល់ *ដីកាសម្រេចលើកលែងចោទប្រកាន់* និងបានបង្គាប់ឲ្យក្រឡាបញ្ជីជាតិនៃ អង្គបុរេជំនុំជម្រះ ជូនដំណឹងទៅផ្នែកគ្រប់គ្រងតុលាការថា សំណុំរឿង ០០៤/២ ត្រូវបានបញ្ចប់ ហើយសំណុំរឿងគួររក្សាទុកក្នុងបណ្ណសារ។ *ការប្រាស្រ័យទាក់ទងតាមអ៊ីមែលរវាង អង្គបុរេជំនុំជម្រះ និង ផ្នែកគ្រប់គ្រងតុលាការ* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០ មានភ្ជាប់ជាឧបសម្ព័ន្ធ ៣។

[7] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[8] *ចម្លើយតប* កថាខណ្ឌ ១២ (ដោយមិនអើពើចំពោះអត្ថិភាពនៃ *ដីកាសម្រេចលើកលែងចោទប្រកាន់* ដែលមិនបានបដិសេធ បណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា "*មានតែ*សម្លេងភាគច្រើនលើសលប់ដែលបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ដែលអាចរារាំងរឿងក្តីនេះមិនឲ្យបន្តទៅមុខដើម្បីជំនុំជម្រះ" [គូសបញ្ជាក់បន្ថែម])។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងចម្លើយតបរបស់ អោ អាន ទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំឲ្យចាត់វាល់វិធានការរដ្ឋបាលទាំងអស់ដែលចាំបាច់ដើម្បីបញ្ជូនសំណុំរឿង ០០៤/២ (អោ អាន) ទៅអង្គជំនុំជម្រះសាលាដំបូង ("ការឆ្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទិននឹងការបញ្ជូនសំណុំរឿង")* ឯកសារ **D359/28 & D360/37** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ កថាខណ្ឌ ៣ ("ដោយសារតែ អង្គបុរេជំនុំជម្រះ មិនបានបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសារសម្លេងភាគច្រើនលើសលប់នោះអង្គជំនុំជម្រះសាលាដំបូងត្រូវតែទទួលយកអនុលោមតាមវិធាន ៧៧(១៣)(ខ) និង ៧៩(១) នៃវិធានផ្ទៃក្នុង ហើយរឿងក្តីនេះនឹងត្រូវបញ្ជូនទៅជំនុំជម្រះ *បើទោះបីជាដីកាសម្រេចលើកលែងចោទប្រកាន់មិនបានបដិសេធក៏ដោយ*" [គូសបញ្ជាក់បន្ថែម])។ *អនុស្សរណៈអន្តរការិយាល័យទាក់ទិននឹងការជូនដំណឹងអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/២ ឯកសារ D29 ខែមករា ឆ្នាំ២០២០* ទំព័រ ៦ ចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ ផ្ញើទៅការិយាល័យរដ្ឋបាលនិងផ្នែកគ្រប់គ្រងតុលាការ មានភ្ជាប់ជាឧបសម្ព័ន្ធ ៤ ("*ដោយមិនគិតដល់*កម្លាំងគតិយុត្តិនៃដីកាសម្រេចលើកលែងចោទប្រកាន់នៅក្នុងសំណុំរឿងកំពុងពិចារណានេះ ដោយសារដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានបដិសេធដោយសម្លេងគាំទ្រភាគច្រើនលើសលប់នេះ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅមានសុពលភាព" និង "*ដោយមិនគិតដល់សេចក្តីណែនាំនានា [សេចក្តីណែនាំរបស់ប្រធាន]* (ដែលហាក់ដូចជាអសារបង់) មិនឲ្យជូនដំណឹងទៅអង្គជំនុំជម្រះសាលាដំបូង និងឲ្យរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ អង្គជំនុំជម្រះសាលដំបូងត្រូវទទួលយក [...] អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង" [គូសបញ្ជាក់បន្ថែម])។

ចៅក្រមជាតិ និងចៅក្រមអន្តរជាតិមានឋានៈស្មើគ្នា និងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់កេរដំណែលទាំងមូលរបស់តុលាការ។

4. មេធាវីការពារស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ បដិសេធទឡ្ហីករណ៍នានានៅក្នុង *ចម្លើយតប* និងបញ្ជាក់ថា វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩(២)(ខ) នៃវិធានផ្ទៃក្នុង។

5. មេធាវីការពារសូមដាក់ការឆ្លើយតបនេះជាភាសាអង់គ្លេសសិន ចំណែកការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់តាមក្រោយឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## ប្រវត្តិនីតិវិធី

6. នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ មេធាវីការពារក្ដីបានដាក់ *សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ("សំណើសុំ")* របស់ខ្លួន[9]។

7. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ *ចម្លើយតប*។

8. នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ បានផ្ញើ *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ ទាក់ទិននឹងការបញ្ជូនសំណុំរឿង ០០៤/២ ("អនុស្សរណៈអន្តរការិយាល័យថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០")* ទៅភាគីទាំងអស់ និងបានចម្លងជូនការិយាល័យរដ្ឋបាល ក្រឡាបញ្ជីអង្គជំនុំជម្រះសាលាដំបូង និងចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ[10]។ នៅក្នុងអនុស្សរណៈនេះ ចៅក្រមអន្តរជាតិបានបង្ហាញអង្គហេតុបន្ថែមទៀតទាក់ទិននឹងភាពជាប់គាំងបច្ចុប្បន្ននៅក្នុងសំណុំរឿងនេះ និងបានពន្យល់ម្ដងទៀតពីមូលហេតុដែលចៅក្រមអន្តរជាតិជឿថា សំណុំរឿងនេះត្រូវតែបញ្ជូនទៅអង្គជំនុំជម្រះសាលាដំបូង[11]។ ទោះបីមេធាវីការពារ

---

[9] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៦០) *សំណើសុំការបញ្ជាក់ថា បានចាត់វិធានការរដ្ឋបាលដែលចាំបាច់ទាំងអស់ដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ ("សំណើសុំ")* ឯកសារ **D359/27 & D360/36** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

[10] *អនុស្សរណៈអន្តរការិយាល័យថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០* ទំព័រ ១។

[11] *អនុស្សរណៈអន្តរការិយាល័យថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០* ទំព័រ ២៥, ២៦ ឯកសារបន្ថែម ១-៨។

ក្តីកោតសរសើរពីការបញ្ជាក់បំភ្លឺរបស់ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះក្តី តែអនុស្សរណៈនេះពុំមានអានុភាពគតិយុត្តិទេ។ ការិយាល័យរដ្ឋបាល ឬអង្គជំនុំជម្រះសាលាដំបូង ពុំមានកាតព្វកិច្ចអនុវត្តសកម្មភាពឡើយ។ *ការធ្វើសកម្មភាពដោយផ្អែកលើសម្លេងភាគតិចនៃចៅក្រមអង្គបុរេជំនុំជម្រះ និងដោយគ្មានសេចក្តីសម្រេចតាមផ្លូវតុលាការ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើកាតព្វកិច្ច*។

9. នៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ប្រធាន អង្គបុរេជំនុំជម្រះ បានធ្វើ *អនុស្សរណៈចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ទាក់ទិននឹងការបញ្ជាក់សាជាថ្មីទៅលើសេចក្តីសម្រេចលើសំណុំរឿង ០០៤/២ ("អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០")* ដោយគាត់បានបញ្ជាក់សាជាថ្មីថា មានតែការសម្រេចសេចក្តីរួមទេដែលមានប្រសិទ្ធភាពតាមផ្លូវច្បាប់ថា *មតិយោបល់ដោយឡែករបស់ចៅក្រមដែលភ្ជាប់ទៅនឹងការសម្រេចសេចក្តីរួមគ្មានប្រសិទ្ធភាពតាមផ្លូវច្បាប់ទេ* ហើយថា សំណុំរឿង ០០៤/២ ត្រូវបានបញ្ចប់យ៉ាងមានប្រសិទ្ធភាពនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩[12]។

## ច្បាប់ជាធរមាន

10. វិធាន ៦៩(២)(ខ) ចែងថា "នៅពេលដែលគ្មានបណ្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតត្រូវបិទសំណុំរឿងដោយមានបោះត្រាលើសំណុំរឿង និង [...] ប្រសិនបើមានដីកាលើកលែងការចោទប្រកាន់ សំណុំរឿងត្រូវបានរក្សាទុកក្នុងបណ្ណសារ ក្រោយពីផុតរយៈពេលធ្វើបណ្តឹងឧទ្ធរណ៍"។ ពុំមានបទប្បញ្ញត្តិស្មើគ្នាចំពោះស្ថានភាពដែលដីកាសម្រេចលើកលែងចោទប្រកាន់ត្រូវបានបញ្ជាក់ ឬមិនត្រូវបានបដិសេធដោយបណ្តឹងឧទ្ធរណ៍នោះឡើយ។ ហេតុនេះ វិធាន៦៩(២)(ខ) នៃវិធានផ្ទៃក្នុងអនុវត្តដូចគ្នានៅក្នុងសំណុំរឿងរបស់ អោ អាន។

11. វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានទេ *លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ* សេចក្តីសម្រេចដែលមិនមានសំឡេងគាំទ្ររបស់អង្គជំនុំជម្រះត្រូវតម្កល់ទុកជាបានការ។

12. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា "វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"។ គោលការណ៍ដូចគ្នានេះត្រូវបានទទួលយកជាសាកល ដោយមានចែងនៅក្នុង

---

[12] *អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០*។

មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

## ការឆ្លើយតប

13. *សំណើ* របស់ អោ អាន មិនបានមើលរម្លងក្របខណ្ឌច្បាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬមិនបានធ្វើឡើងមុនពេលកំណត់ឡើយ[13]។ សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសម្តងទៀតចំពោះអ្វីដែលហៅថាគោលជំហរស្វ័យប្រវត្តិរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយល់ខុសចំពោះគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងមិនអើពើចំពោះអង្គហេតុដែលថា សំណុំរឿងនេះត្រូវបានបញ្ចប់យ៉ាងមានប្រសិទ្ធភាពត្រឹមថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០១៩ ហើយត្រូវតែយកមករក្សាទុកក្នុងបណ្ណសារ[14]។

### ក. សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសម្តងទៀតចំពោះអ្វីដែលហៅថាគោលជំហរស្វ័យប្រវត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

14. នៅក្នុង *ចម្លើយតប* សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសម្តងទៀតចំពោះអ្វីដែលហៅថាគោលជំហរស្វ័យប្រវត្តិរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបដិសេធអត្ថិភាពនៃ *ដីកាសម្រេចលើកលែងចោទប្រកាន់*[15]។ អ្វីដែលហៅថាគោលជំហរស្វ័យប្រវត្តិអនុវត្តចំពោះយន្តការដោះស្រាយករណីខ្វែងយោបល់នៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចបានពន្យល់ដោយផ្នែកនៃប្រវត្តិនៃការចរចាដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានដកស្រង់នៅក្នុង *ចម្លើយតប*[16]។ វាមិនអនុវត្តចំពោះស្ថានភាពបច្ចុប្បន្ន ដែលមានដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នានិងផ្ទុយគ្នាដែលមិនត្រូវបានបដិសេធដោយការសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នោះទេ[17]។

15. ការដែលនៅតែរក្សាជំហរថា គោលជំហរស្វ័យប្រវត្តិនេះនៅតែយកមកអនុវត្តនោះសហព្រះរាជអាជ្ញាអន្តរជាតិ កំពុងអះអាងថា យោបល់របស់ចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ នៅក្នុង *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍* មានអានុភាពគតិយុត្តិជាងការសម្រេចសេចក្តីរួម និងយោបល់

---

[13] *ចម្លើយតប* កថាខណ្ឌ ១២, ១៧។

[14] *ចម្លើយតប* កថាខណ្ឌ ១២, ១៦, ១៧។

[15] *ចម្លើយតប* កថាខណ្ឌ ១៣។

[16] *ចម្លើយតប* កថាខណ្ឌ ៣ ជើងទំព័រ ១៣។

[17] *ចម្លើយតប* កថាខណ្ឌ ១៧។

របស់ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ[18]។ ដូចបានកត់សម្គាល់នៅក្នុង *សំណើសុំ* គឺថា អង្គបុរេជំនុំជម្រះ បានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា ជារឿងខុសច្បាប់ តែអង្គជំនុំជម្រះមិនអាចរកបានសម្លេងភាគច្រើនលើសលប់ ដើម្បីសម្រេចទៅលើអានុភាពនៃភាពខុសច្បាប់នេះ និងផលវិបាកផ្នែកនីតិវិធីសម្រាប់សំណុំរឿង ០០៤/២ បានឡើយ[19]។ នៅក្នុង *អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០* និង *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០* ប្រធាន អង្គបុរេជំនុំជម្រះ បានបញ្ជាក់ថា មានតែការសម្រេចសេចក្តីរួមគ្នាដែលត្រូវបានសម្រេច និងចុះហត្ថលេខាដោយចៅក្រមទាំងប្រាំរូបទេ ទើបមាន "ប្រសិទ្ធភាពអនុវត្ត" ហើយថា "ការជូនដំណឹងទៅបុគ្គល ឬអង្គជំនុំជម្រះណាក៏ដោយដែលមិនមែនជាភាគីនៃសំណុំរឿងនេះ [រំលោភ]ទៅលើសេចក្តីសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ"[20]។ ទាំង សហព្រះរាជអាជ្ញាអន្តរជាតិ ទាំង ចៅក្រមអន្តរជាតិនៃ អង្គបុរេជំនុំជម្រះ បានបង្ហាញនូវមូលដ្ឋានមានសុពលភាពនៅក្នុងច្បាប់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីសន្និដ្ឋានថា មតិភាគតិចរបស់ចៅក្រមអន្តរជាតិនៅ អង្គបុរេជំនុំជម្រះ មានអាទិភាពជាងការសម្រេចសេចក្តីរួម និងមតិភាគច្រើនរបស់ចៅក្រមជាតិនៃ អង្គបុរេជំនុំជម្រះ។

16. ចុងក្រោយ មេធាវីការពារក្តីទទួលស្គាល់ថា យោបល់ផ្សេងគ្នារវាងចៅក្រមភាគច្រើន-ភាគតិចនៅ អង្គបុរេជំនុំជម្រះ មិនមែនជាកត្តាសម្រេចនៅក្នុងសំណុំរឿងរបស់ អោ អាន ទេ វាក៏មិនមែន "មិនពាក់ព័ន្ធ" ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងនោះដែរ[21]។ ផ្ទុយទៅវិញយោបល់ផ្សេងគ្នានេះគួរឲ្យកត់សម្គាល់នៅក្នុងស្ថានភាពបច្ចុប្បន្នដែលក្របខណ្ឌគតិយុត្តិនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនអាចដោះស្រាយភាពជាប់គាំងបច្ចុប្បន្នបាន ហើយដែល សហព្រះរាជអាជ្ញាអន្តរជាតិ និង ចៅក្រមអន្តរជាតិនៅ អង្គបុរេជំនុំជម្រះ នៅតែបន្តមិនអើពើទៅលើអត្ថិភាព និងភាពអាចអនុវត្តបាននៃ *ដីកាសម្រេចលើកលែងចោទប្រកាន់*។

---

[18] *ចម្លើយតប* កថាខណ្ឌ ១២, ១៤។

[19] *សំណើសុំ* កថាខណ្ឌ ១៦។

[20] *អនុស្សរណៈថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០* ទំព័រ ២។ *អនុស្សរណៈអន្តរការិយាល័យចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ទាក់ទិននឹងការបញ្ជាក់បំភ្លឺនៅក្នុងសេចក្តីសម្រេចក្នុងសំណុំរឿង ០០៤/២* ដែលប្រធាន អង្គបុរេជំនុំជម្រះ បានផ្ញើជូនផ្នែកគ្រប់គ្រងតុលាការ ទំព័រ ២ មានភ្ជាប់ជាឧបសម្ព័ន្ធ ៥។

[21] *ចម្លើយតប* កថាខណ្ឌ ១២, ១៤។

## ខ. គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* អនុវត្តចំពោះភាពជាប់គាំងនាពេលបច្ចុប្បន្ន នៅក្នុងសំណុំរឿងរបស់ អោ អាន

17. គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តភាពចំពោះភាពជាប់គាំងទាក់ទិននឹងវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុងនៅក្នុងកិច្ចដំណើរការនីតិវិធីមុនការជំនុំជម្រះនាពេលបច្ចុប្បន្នប្រឆាំងនឹង អោ អាន។ ផ្ទុយពីការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* មិនអនុវត្តតែចំពោះវិមតិសង្ស័យលើអង្គហេតុនៅឯដំណាក់កាលជំនុំជម្រះទាក់ទិននឹងការចោទប្រកាន់ពីពិរុទ្ធភាពរបស់ អោ អាន ប៉ុណ្ណោះទេ តែការអនុវត្តគោលការណ៍នេះនៅក្នុងសំណុំរឿងរបស់ អោ អាន មិនមែនជា "សេចក្តីសន្និដ្ឋានយកជាការដោយស្វ័យប្រវត្តិ" ឬ រំលោភបំពានទៅលើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើយ[22]។

18. មានការបង្ហាញយ៉ាងត្រឹមត្រូវនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាថាគោលការណ៍ជាសារវ័ន្តនានាដែលត្រូវបានការពារនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង និង មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា រួមមានសច្ចាធារណ៍នៃនិរទោស និង គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលអនុវត្តទាំងនៅដំណាក់កាលមុនការជំនុំជម្រះ និងដំណាក់កាលជំនុំជម្រះនៃកិច្ចដំណើរការនីតិវិធី[23]។

19. លើសពីនេះទៀត គោលការណ៍ជាសារវ័ន្តនៃច្បាប់សារធាតុផ្នែកព្រហ្មទណ្ឌ ដូចជាគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការហាមឃាត់ការអនុវត្តច្បាប់បែបប្រតិសកម្ម ក៏អាចពង្រីកដល់ច្បាប់នីតិវិធីដែរ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀតបានអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជន*

---

[22] *ចម្លើយតប* កថាខណ្ឌ ១៦ (បញ្ចូលទឡ្ហីករណ៍ពី *ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទិននឹងការបញ្ជូនសំណុំរឿង* កថាខណ្ឌ ៦-៧)។

[23] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៤២) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី* ឯកសារ **D264/2/6** ចុះថ្ងៃទី១០ ខែសីហា ២០១០ កថាខណ្ឌ ១៣ មានភ្ជាប់ជាឧបសម្ព័ន្ធ ៦។ *រឿងក្តី Vera Fernández-Huidobro ទល់នឹង ប្រទេសអេស្ប៉ាញ* តុលាការ ECtHR លេខ 74181/01 ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ១០៨-១១៣ មានភ្ជាប់ជាឧបសម្ព័ន្ធ ៧។

*ជាប់ចោទ* ចំពោះស្ថានភាពលំបាកនៃអង្គហេតុ និងច្បាប់សារធាតុ ព្រមទាំងច្បាប់នីតិវិធីផងដែរ[24]។ ការអនុវត្តនេះស្របទៅនឹងការអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* នៅក្នុងមាត្រា ២២ នៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលឆ្លុះបញ្ចាំងពីបទដ្ឋានដែលត្រូវបានទទួលយកជាអន្តរជាតិ[25]។

20. ចុងក្រោយ ទោះបីមេធាវីការពារក្តីនៅតែរក្សាជំហរថា អនុលោមតាមវិធាន ៧៧(១៣)(ខ) នៃវិធានផ្ទៃក្នុង *ដីកាសម្រេចលើកលែងចោទប្រកាន់* នៅមានសុពលភាព ហើយសំណុំរឿងនេះត្រូវ

---

[24] ***ច្បាប់សារធាតុ៖*** សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក (០៤) *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខផ្ទាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ឯកសារ E50/3/1/4 ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣១ (សម្រេចថា "ចំពោះគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃអត្ថន័យច្បាប់ គោលការណ៍នេះត្រូវកម្រិតត្រឹមតែភាពមន្ទិលសង្ស័យដែលនៅតែមានក្រោយការបកស្រាយ" [លុបចោលអត្ថបទដកស្រង់ខាងក្នុង] មានភ្ជាប់ជាឧបសម្ព័ន្ធ ៨។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ១៤៥ & ១៤៦) *សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ* ឯកសារ D427/2/15 ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ១៤៤ មានភ្ជាប់ជាឧបសម្ព័ន្ធ ៩ (សម្រេចថាតើលក្ខខណ្ឌតម្រូវនៃចំណងពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានភាពមិនច្បាស់លាស់គ្រប់គ្រាន់ដើម្បីចោទប្រកាន់ជនជាប់ចោទ ឬយ៉ាងណា)។ ***ច្បាប់នីតិវិធី៖*** *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Ruto & Sang* សំណុំរឿងលេខ ICC-01/09-01/11 OA 10 ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ៩៤-៩៨ មានភ្ជាប់ជាឧបសម្ព័ន្ធ ១០ (ហាមឃាត់ ការអនុវត្តបែបប្រតិសកម្មទៅលើវិធាននីតិវិធីទាក់ទិននឹងការទទួលយកភស្តុតាង ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ជនជាប់ចោទ)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Tadić* សំណុំរឿងលេខ IT-94-1-A *សេចក្តីសម្រេចលើសំណើរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍សុំពន្យារពេលវេលាកំណត់ និងការទទួលយកភស្តុតាងបន្ថែម* ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៨ មានភ្ជាប់ជាឧបសម្ព័ន្ធ ១១ (លើកឡើងនៅក្នុងករណីមានវិមតិសង្ស័យពាក់ព័ន្ធនឹងការអនុវត្តលក្ខណៈវិនិច្ឆ័យនានាសម្រាប់ការទទួលយកភស្តុតាង គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* យកមកអនុវត្ត)។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T *សាលក្រមអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៣១៩ មានភ្ជាប់ជាឧបសម្ព័ន្ធ ១២ (អនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* យ៉ាងទូលំទូលាយចំពោះការបកស្រាយស្រពិចស្រពិលនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងលើកឡើងថា "គោលការណ៍ទូទៅនៃច្បាប់ចែងថា នៅក្នុងបញ្ហាព្រហ្មទណ្ឌ សំណៅដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទគួរត្រូវបានជ្រើសរើស")។

[25] លក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ (វិសោធនកម្មចុងក្រោយឆ្នាំ២០១០) ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ISBN No. 92-9227-227-6 មាត្រា ២២(២) ("និយមន័យនៃបទល្មើសព្រហ្មទណ្ឌ ត្រូវតែបកស្រាយអធិប្បាយឱ្យល្អិត ហើយមិនត្រូវពង្រីកវិសាលភាព ដោយសារពន្យល់ប្រៀបធៀប (analogy) ឡើយ។ នៅក្នុងករណីមានវិមតិសង្ស័យ ការកំណត់និយមន័យនោះ ត្រូវបកស្រាយជាប្រយោជន៍ដល់ជនដែលកំពុងត្រូវរងការធ្វើការស៊ើបអង្កេត ត្រូវនាំយកមកជំនុំជម្រះ ឬ ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាព")។

បានបញ្ចប់នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ក៏ដោយ តែក្នុងករណីដែល *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* នៅមានសុពលភាព អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងដែរនោះ គោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ត្រូវយកមកអនុវត្ត ហើយភាពជាប់គាំងបច្ចុប្បន្នត្រូវដោះស្រាយជាប្រយោជន៍របស់ អោ អាន។ ការអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ* ជួយពង្រឹងបន្ថែមទៀតដល់សិទ្ធិរបស់ អោ អាន ក្នុងការទទួលការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ចដែលបង្កើតឡើងដោយច្បាប់ ដែលតម្រូវឱ្យកិច្ចដំណើរការនីតិវិធីត្រូវធ្វើឡើងទៅតាមវិធានច្បាប់។ ហេតុនេះ វាមិនត្រឹមតែពាក់ព័ន្ធដែលថា ពុំទទួលបានសម្លេងភាគច្រើនលើសលប់ ដើម្បីបដិសេធ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឬ *ដីកាសម្រេចលើកលែងចោទប្រកាន់* ប៉ុណ្ណោះទេ តែវាក៏ពាក់ព័ន្ធផងដែរថា *ដីកាសម្រេចលើកលែងចោទប្រកាន់* ត្រូវបានតម្កល់ដោយការគាំទ្រពីចៅក្រមសម្លេងភាគច្រើននៃអង្គបុរេជំនុំជម្រះ។

### គ. *សំណើសុំ* មិនបានធ្វើឡើងមុនពេលកំណត់ឡើយ

21. មេធាវីការពារក្តីមិនបានដាក់ *សំណើសុំ* មុនពេលកំណត់ឡើយ។ សំណុំរឿង ០០៤/២ ត្រូវបានលើកលែងចោទប្រកាន់យ៉ាងមានប្រសិទ្ធភាពកាលពីជិតបីខែមុន នៅពេលដែលចៅក្រមអង្គបុរេជំនុំជម្រះចេញ *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍*។ បន្ទាប់ពីការលើកលែងចោទប្រកាន់យ៉ាងមានប្រសិទ្ធភាពនោះមក សំណុំរឿងនេះគួរត្រូវបានរក្សាទុកក្នុងបណ្ណសារ អនុលោមតាមវិធាន ៦៩ (២)(ខ) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាននេះ ប្រធាន អង្គបុរេជំនុំជម្រះ និង ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះ (ដែលបង្កើតជាសម្លេងភាគច្រើន) បានណែនាំដល់ក្រឡាបញ្ជីជាតិឱ្យជូនដំណឹងដល់ផ្នែកគ្រប់គ្រងតុលាការថា សំណុំរឿង ០០៤/២ ត្រូវបានបញ្ចប់ ហើយថា សំណុំរឿងនេះគួររក្សាទុកក្នុងបណ្ណសារ[26]។ ទោះជាយ៉ាងណាក្តី មកទល់នឹងពេលនេះ សកម្មភាពនេះមិនទាន់បានកើតឡើងនៅឡើយទេ។

## សេចក្តីសន្និដ្ឋាន និង សំណើ

22. អនុលោមតាមសំអាងហេតុនានាខាងលើ មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះមេត្តា បដិសេធទឡ្ហីករណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ នៅក្នុង *ចម្លើយតប* និងបញ្ជាក់ថា

[26] *ការប្រាស្រ័យទាក់ទងតាមអ៊ីម៉ែលរវាង អង្គបុរេជំនុំជម្រះ និង ផ្នែកគ្រប់គ្រងតុលាការ* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០។

វិធានការរដ្ឋបាលដែលត្រូវការទាំងអស់ត្រូវបានធ្វើឡើងដើម្បីរក្សាសំណុំរឿង ០០៤/២ ទុកក្នុងបណ្ណសារ។

សូមលោកចៅក្រមមេត្តាទទួលយកការឆ្លើយតបនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០

**សហមេធាវីការពារក្តី អោ អាន**

| | | |
|---|---|---|
| មុំ លុជ្ជ | Richard ROGERS | Göran SLUITER |